# បញ្ញាបន្តិចបន្តួច

ប្រធាន ដាយធើ អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

*ភាពខុសគ្នារវាងសុភមង្គល និងអពមង្គល... ជាញឹកញាប់កើតឡើង ដោយសារកំហុសតែបន្តិចបន្តួចប៉ុណ្ណោះ*

បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំទទួលអារម្មណ៍នូវកម្លាំង និងសេចក្ដីល្អរបស់អ្នករាល់គ្នា ពេលដែលយើងជួបជុំគ្នាក្នុងនាមជាអ្នកកាន់បព្វជិតភាពនៃព្រះ ។ ខ្ញុំស្រឡាញ់អ្នករាល់គ្នា ខ្ញុំសូមកោតសរសើរដល់អ្នករាល់គ្នា។ សូមថ្លែងអំណរគុណចំពោះសេចក្ដីជំនឿ ការអធិស្ឋាន និងឆន្ទៈរបស់អ្នករាល់គ្នាដើម្បីបំរើព្រះអម្ចាស់ ។

ចាប់តាំងពីប្រធាន ថូម៉ាស អេស ម៉នសុន បានហៅរូបខ្ញុំឱ្យបំរើជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយនៃសាសនាចក្រ ឥឡូវវាមានរយៈពេលពីរខែមកហើយ ។ ខ្ញុំជឿជាក់ថាការណ៍នេះធ្វើឱ្យមានការភ្ញាក់ផ្អើលដល់មនុស្សជាច្រើន ហើយខ្ញុំក៏មានការភ្ញាក់ផ្អើលផងដែរ ។ តាមពិត ខ្ញុំសូមនិយាយថា ខ្ញុំអាចជាមនុស្សទីពីរនៅលើផែនដី ដែលមានការភ្ញាក់ផ្អើលបំផុត ភរិយារបស់ខ្ញុំជាមនុស្សទីមួយ ។

នៅថ្ងៃដែលក្រុមសាវក 12 នាក់ ជួបជុំគ្នានៅក្នុងព្រះវិហារបរិសុទ្ធ ដើម្បីគាំទ្រប្រធាន ម៉នសុន និងតែងតាំង ហើយធ្វើពិធីញែកចេញឱ្យលោក ជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ហើយជាប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ខ្ញុំមានសេចក្ដីរីករាយយ៉ាងខ្លាំង ដែលមានឱកាសលើកដៃរបស់ខ្ញុំគាំទ្រមិត្ត និងអ្នកដឹកនាំ ជាទីស្រឡាញ់របស់ខ្ញុំ ។

បន្ទាប់ពីប្រធាន ម៉នសុន ត្រូវបានគាំទ្រ លោកបានប្រកាសនូវទីប្រឹក្សាទាំងពីររបស់លោក ។ ប្រធាន អាវរិង ពុំមានការភ្ញាក់ផ្អើលឡើយ ។ លោក គឺជាបុរសនៃភាពខ្ពង់ខ្ពស់ និងនិស្ស័យល្អ---ជាជំរើសដ៏ល្អបំផុតដើម្បីធ្វើជាទីប្រឹក្សាទីមួយ ។ ខ្ញុំស្រឡាញ់ និងកោតសរសើរលោកខ្លាំងណាស់ ។

បន្ទាប់មកប្រធាន ម៉នសុន បានប្រកាសនូវទីប្រឹក្សាទីពីររបស់លោក ។ វាជាឈ្មោះដែលចម្លែកដូចជាធ្លាប់ស្គាល់ ។ នោះជាឈ្មោះរបស់ខ្ញុំ ។

ខ្ញុំបានសម្លឹងមើលជុំវិញបន្ទប់នោះ ដោយមិនប្រាកដថាខ្ញុំបានឮត្រឹមត្រូវឡើយ ។ ប៉ុន្តែស្នាមញញឹមពីសំណាក់បងប្អូនប្រុសរបស់ខ្ញុំ និងការបង្ហាញនៃសេចក្ដីមេត្តាចេញពីប្រធាន ម៉នសុន បានធ្វើឱ្យខ្ញុំប្រាកដថា ឆាកជីវិតរបស់ខ្ញុំរៀបនឹងផ្លាស់ប្ដូរម្ដងទៀតហើយ ។ យើងទាំងអស់គ្នានឹកដល់ប្រធាន ហ៊ិងគ្លី ។ លោកបន្តប្រទានពរដល់ជីវិតរបស់យើង ។

ប្រធាន ម៉នសុន គឺជាព្យាការីនៃព្រះសំរាប់ជំនាន់របស់យើង ខ្ញុំគោរពលោក ហើយសន្យាដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងចំពោះកិច្ចការដ៏មហិមានេះ ។

នៅក្នុងឆ្នាំ 1979 ក្រុមអ្នកដំណើរតាមយន្តហោះដ៏ធំមួយ ដែលមានមនុស្ស 257 នាក់នៅលើយន្តហោះ បានចេញដំណើរពី ញូហ្ស៊ីឡែន សំរាប់ការហោះហើរមើលទេសភាពមួយទៅកាន់ អង់តាកទិកា ហើយត្រឡប់មកវិញ ។ ប៉ុន្តែមានបុគ្គលម្នាក់បានផ្លាស់ប្ដូរកូរ៉ដោនៃការហោះតែពីរដឺក្រេប៉ុណ្ណោះ ដែលពុំបានជូនដំណឹងដល់អ្នកបើកបរយន្តហោះសោះ ។ កំហុសនេះបាននាំយន្តហោះនោះឆ្ពោះទៅទិសខាងកើត ដែលចម្ងាយ 28 ម៉ៃល (45 គ.ម.) នៃទីតាំងដែលអ្នកបើកបរ

បានស្មានទុកជាមុន។ ពេលដែលពួកគេទៅជិតដល់ អង់តាកទិកា អ្នកបើកបរបានបន្ទាបខ្លួនយន្តហោះឱ្យនៅកំពស់ទាប បន្តិច ដើម្បីឱ្យអ្នកធ្វើដំណើរអាចមើលឃើញទិដ្ឋភាពដ៏ស្រស់ស្អាត នៃវាលទំនាប។ ទោះបីជាអ្នកបើកបរទាំងពីរមាន បទពិសោធន៍ច្រើនក្នុងការហោះហើរ ប៉ុន្តែក្នុងចំណោមពួកគេទាំងពីរនាក់ គ្មាននរណាម្នាក់ធ្លាប់បើកយន្តហោះប្រភេទនេះ ពីមុនឡើយ ហើយពួកគេគ្មានផ្លូវនឹងដឹងថា ក៏រិតនៃការហោះហើរមិនត្រឹមត្រូវបាននាំពួកគេទៅកាន់ភ្នំ អេរ៉េប៊ុស ជាភ្នំភ្លើង កំពុងផ្ទុះចេញពីទីវាលទំនាបដែលកកមានកំពស់ជាង 3,700 ម៉ែត្រ។

ពេលដែលអ្នកបើកបរបន្តការហោះហើរ នោះដុំព្រិល និងទឹកកកពណ៌សដែលគ្របពីលើភ្នំភ្លើងនោះ បានផ្គុំគ្នា ជាមួយនឹងដុំពពកសនៅខាងលើ វាបង្កើតជាទិដ្ឋភាពមួយហាក់ដូចជាពួកគេកំពុងហោះហើរនៅលើដីរាបស្មើ។ ពេលដែល ឧបករណ៍បានបន្លឺនូវសម្លេងអាសន្នថា ដីរាបស្មើនោះកំពុងដុះឡើងយ៉ាងលឿនតំរង់មកកាន់ពួកគេនោះ វាបានយឺតពេល ទៅហើយ។ យន្តហោះនោះ បានហោះទៅបុកនឹងភ្នំភ្លើង ដោយបានសំលាប់មនុស្សទាំងអស់ នៅលើយន្តហោះនោះ។

វាគឺជាសោកនាដកម្មដ៏អាណោចអធមដែលបានកើតឡើងដោយសារតែកំហុសបន្តិចបន្តួច---ជាបញ្ហាតែបន្តិច បន្តួចប៉ុណ្ណោះ។[1]

តាមរយៈការបំរើព្រះអម្ចាស់អស់រយៈពេលជាច្រើនឆ្នាំ និងនៅក្នុងការសម្ភាសន៍រាប់មិនអស់ ខ្ញុំបានរៀនថា ភាពខុសគ្នារវាងសុភមង្គល និងទុក្ខវេទនាជាបុគ្គល នៅក្នុងអាពិពាហ៍ពិពាហ៍ និងក្រុមគ្រួសារ ជាញឹកញាប់កើតឡើង ដោយសារកំហុសតែបន្តិចបន្តួចប៉ុណ្ណោះ។

## សូល ជាស្តេចនៃអ៊ីស្រាអែល

រឿងនិទានរបស់សូល ជាស្តេចនៃអ៊ីស្រាអែល បង្ហាញនូវចំណុចដូចគ្នានេះ។ ឆាកជីវិតរបស់សូល បានចាប់ផ្តើមជាមួយនឹង សេចក្តីសន្យាដ៏មហិមា ប៉ុន្តែរឿងនេះមាននូវទីបញ្ចប់ដ៏អភ័ព្វ និងប្រកបដោយសោកនាដកម្ម។ កាលពីដើម សូល "មានរូប ឆោមល្អណាស់ ...ក្នុងបណ្តាពួកកូនចៅអ៊ីស្រាអែល គ្មានអ្នកណាល្អជាងទេ"។[2] សូល ត្រូវបានជ្រើសរើសផ្ទាល់ដោយព្រះ ដើម្បីធ្វើជាស្តេច។[3] ទ្រង់មានគុណសម្បត្តិជាច្រើន---ទ្រង់មានមាឌធំ[4] ហើយទ្រង់ចេញមកពីគ្រួសារដែលមានឥទ្ធិពល។[5]

ពិតប្រាកដណាស់ សូលមាននូវភាពទន់ខ្សោយ ប៉ុន្តែព្រះអម្ចាស់បានសន្យានឹងប្រទានពរ លើកដំកើង និងធ្វើឱ្យ ទ្រង់រុងរឿង។ បទគម្ពីរទាំងឡាយប្រាប់យើងថា ព្រះបានសន្យាថានឹងគង់ជាមួយទ្រង់ជានិច្ច[6] ផ្តល់ឱ្យទ្រង់នូវដួងចិត្ត មួយទៀត[7] ហើយធ្វើឱ្យទ្រង់ក្លាយជាមនុស្សថ្មីម្នាក់ទៀត។[8] នៅពេលដែលទ្រង់មាននូវជំនួយរបស់ព្រះអម្ចាស់ សូលគឺជា ស្តេចដ៏អស្ចារ្យមួយអង្គ។ ទ្រង់បានបង្រួបបង្រួមអ៊ីស្រាអែល ហើយបានវាយបណ្តេញសាសន៍អាំម៉ូន ដែលបានឈ្លានពាន ដែនដីរបស់ពួកគេ។[9] មិនយូរប៉ុន្មាន មានបញ្ហាធំៗជាច្រើនបានកើតឡើងចំពោះទ្រង់---ពួកភីលីស្ទីន ដែលមានកងទ័ព ដ៏កាចសាហាវ ប្រដាប់ដោយរទេះចម្បាំង និងពលសេះ ហើយនឹង "ពលថ្មើរជើងសន្ធឹកណាស់ដូចជាខ្សាច់ដែលនៅមាត់ សមុទ្រ"។[10] ពួកអ៊ីស្រាអែលមានការភ័យខ្លាចយ៉ាងខ្លាំងចំពោះពួកភីលីស្ទីន រហូតដល់ពួកគេ "បានរត់ទៅជ្រកពួនក្នុង រអាង ក្នុងព្រៃញាតស្បាត ក្នុងកន្លៀតថ្ម"។[11]

ស្តេចវ័យក្មេងរូបនេះត្រូវការជំនួយ។ ព្យាការី សាំយូអែល បានផ្ញើសារថាឱ្យទ្រង់ចាំសិន ហើយថាគាត់ដែលជាព្យាការី នឹងមកដើម្បីថ្វាយយញ្ញបូជា និងរកនូវពាក្យទូន្មានពីព្រះអម្ចាស់។ សូលបានរង់ចាំអស់រយៈពេលប្រាំពីរថ្ងៃ ហើយព្យាការី សាំយូអែល នៅតែមិនទាន់មកដល់។ ទីបំផុត សូលទទួលអារម្មណ៍ថា ទ្រង់មិនអាចរង់ចាំទៀតបានឡើយ។ ទ្រង់បាន

ប្រមូលប្រជាជន ហើយបានធ្វើនូវអ្វីមួយដែលទ្រង់គ្មានសិទ្ធិអំណាចបព្វជិតភាពដើម្បីធ្វើ---ទ្រង់បានថ្វាយយញ្ញបូជាដោយខ្លួនឯង។

នៅពេលដែលសាំយូអែលបានមកដល់ គាត់មានការខកចិត្តយ៉ាងខ្លាំង។ គាត់បាននិយាយថា "ទ្រង់បានប្រព្រឹត្តនេះវរគំនិត ហើយ" ។ ប្រសិនបើស្តេចថ្មីតស៊ូដល់ទីបំផុតតែបន្តិចទៀតប៉ុណ្ណោះ ហើយមិនបានវេចេញពីផ្លូវរបស់ព្រះអម្ចាស់ ប្រសិនបើ ទ្រង់បានធ្វើតាមបទបញ្ជានៃបព្វជិតភាពដែលបានបើកសម្តែង នោះព្រះអម្ចាស់នឹងស្ថាបនានគររបស់ទ្រង់ជារៀងរហូតតទៅ។ សាំយូអែលបាននិយាយថា "តែឥឡូវនេះ រាជ្យទ្រង់មិនបាននៅតទៅទៀតទេ" ។[12]

នៅសម័យនោះ ព្យាការីសាំយូអែល បានដឹងនូវសេចក្តីទន់ខ្សោយប្រកបដោយគ្រោះថ្នាក់មួយនៅក្នុងឥរិយាបទរបស់សូល។ នៅពេលដែលបានអូសទាញដោយឥទ្ធិពលខាងក្រៅ សូលមិនមានការគ្រប់គ្រងលើខ្លួនឯងដើម្បីជឿទុកចិត្តព្រះអម្ចាស់ និងព្យាការីរបស់ទ្រង់ ហើយធ្វើតាមគំរូដែលព្រះបានស្ថាបនាឡើង។

## កំហុសតូចតាចអាចមានឥទ្ធិពលដ៏ធំចំពោះជីវិតរបស់យើង

ភាពខុសប្លែកតែបន្តិចបន្តួចដូចទឹងជើងយន្តហោះដែលហោះហើរទៅអាន់តាកទីកា ឬការបរាជ័យរបស់សូលក្នុងការកាន់ខ្ជាប់ចំពោះពាក្យទូន្មានរបស់ព្យាការីតែបន្តិច អាចឃើញថាបន្តិចបន្តួច។ ប៉ុន្តែសូម្បីតែកំហុសតូចៗជារៀងរាល់លើក វាអាចបង្កើតនូវភាពខុសគ្នា នៃវិនាសកម្មនៅក្នុងឆាកជីវិតរបស់យើង។

ខ្ញុំសូមចែកចាយជាមួយនឹងអ្នករាល់គ្នានូវរបៀបដែលខ្ញុំបានបង្រៀនគោលការណ៍ដូចគ្នានេះ ទៅដល់អ្នកបើកបរយន្តហោះវ័យក្មេងទាំងឡាយ។

ឧបមាថាអ្នករាល់គ្នាបានរៀបចំធ្វើដំណើរចេញពីអាកាសយាន្តដ្ឋាននៅខ្សែអេក្វាទ័រ ដោយមានបំណងហោះហើរទៅជុំវិញពិភពលោក ប៉ុន្តែផ្លូវរបស់អ្នកបានឃ្លាតចេញតែមួយដឺក្រេ។ ពេលដែលអ្នកបានត្រឡប់មកឯរយៈបណ្តោយដូចគ្នាវិញ តើចម្ងាយប៉ុន្មានដែលអ្នកនឹងខិតចេញពីផ្លូវ? មួយរយម៉ែល? ចំលើយនោះអាចធ្វើអោយអ្នកមានការភ្ញាក់ផ្អើល។ កំហុសតែមួយដឺក្រេនឹងធ្វើឱ្យអ្នកខិតចេញពីផ្លូវជិត 800 គ.ម ឬរយៈពេលមួយម៉ោងសំរាប់យន្តហោះប្រតិកម្មមួយ។

គ្មាននរណាម្នាក់ចង់ឱ្យជីវិតរបស់ខ្លួនត្រូវបញ្ចប់នៅក្នុងសោកនាដកម្មឡើយ។ ប៉ុន្តែជាញឹកញាប់ មនុស្សគ្រប់រូបដូចគ្នានឹងអ្នកបើកបរយន្តហោះ និងពួកអ្នកដំណើរក្នុងការហោះហើរមើលទិដ្ឋភាពផងដែរ យើងកំណត់លើអ្វីដែលយើងគិតថា នឹងមាននូវដំណើរដ៏រីករាយមួយតែប៉ុណ្ណោះ រហូតដល់ពេលដឹង វាយឺតពេលទៅហើយ ថាកំហុសតែបន្តិចបន្តួចបានកំណត់យើងលើផ្លូវមួយដែលជាគ្រោះមហន្តរាយខាងវិញ្ញាណ។

## តើយើងមានមេរៀនមួយនៅក្នុងគំរូទាំងនេះសំរាប់ជីវិតរបស់យើងដែរឬទេ?

កំហុសតូចតាច និងការឃ្លាតចេញឆ្ងាយបន្តិចពីគោលលទ្ធិនៃដំណឹងនៃព្រះយេស៊ូវគ្រីស្ទ អាចនាំមកនូវលទ្ធផលប្រកបដោយទុក្ខព្រួយនៅក្នុងឆាកជីវិតរបស់យើង។ ដូចនេះវាសំខាន់ខ្លាំងណាស់ ដែលយើងត្រូវហ្វឹកហ្វឺន ឱ្យបានគ្រប់គ្រាន់ដើម្បីធ្វើការកែតំរូវឱ្យបានមុន ហើយត្រឹមត្រូវ ដើម្បីត្រលប់ទៅលើផ្លូវដែលត្រូវ ហើយកុំរង់ចាំ ឬសង្ឃឹមថា កំហុសទាំងឡាយនឹងកែតំរូវដោយឯកឯងនោះឡើយ។

កាលយើងយឺតយ៉ាវក្នុងការកែតំរូវសកម្មភាព នោះនឹងមានការកែប្រែជាច្រើនត្រូវធ្វើឡើង ហើយវានឹងចំណាយពេលដ៏យូរដើម្បីត្រឡប់ទៅលើផ្លូវត្រូវវិញ---សូម្បីតែនៅចំណុចមួយដែលគ្រោះមហន្តរាយអាចនឹងរង់ចាំដើម្បីឱ្យកើតឡើង។

អ្នករាល់គ្នាដែលជាបុរសនៃបព្វជិតភាពត្រូវបានផ្តល់នូវទំនុកចិត្តជាមួយនឹងការទទួលខុសត្រូវដ៏ធំមួយ។ សូមគិតអំពីរឿងនេះ : ព្រះវរបិតាសួគ៌របស់យើងទុកចិត្តចំពោះអ្នករាល់គ្នាដែលជា ឌីកុនវ័យក្មេង គ្រូ និងសង្ឃជាមួយនឹង "កូនសោខាងការបំរើនៃពួកទេវតា និងដំណឹងល្អខាងការរៀបចំ"។[13] អ្នករាល់គ្នាដែលជាបុរសនៃបព្វជិតភាពមិលគីស្សាដែកដែលបានទទួលនូវសម្បថ និងសេចក្តីសញ្ញាមួយ ដែលអ្នកត្រូវបានសន្យាឱ្យអ្វីៗទាំងអស់ដែលព្រះវរបិតាមាន ប្រសិនបើអ្នករាល់គ្នាលើកដំកើងបព្វជិតភាពរបស់អ្នក។[14]

ព្រះអម្ចាស់រំឭកយើងថា "ដល់អ្នកណាដែលត្រូវបានប្រទានឱ្យច្រើន នោះក៏មានតម្រូវការជាច្រើនវិញ"។[15] ជនទាំងឡាយណាដែលកាន់បព្វជិតភាពនៃព្រះ មាននូវការទទួលខុសត្រូវដ៏ធំ ដើម្បីធ្វើគំរូនៃសេចក្តីល្អដល់ពិភពលោក។ យើងរស់នៅដោយឆ្ពោះទៅកាន់ការរំពឹងទុកទាំងនេះ ពេលដែលយើងស្គាល់ភ្លាមៗនូវគ្រោះថ្នាក់ និងឥទ្ធិពលទាំងឡាយដែលទាញយើងចេញពីផ្លូវរបស់ព្រះអម្ចាស់ និងពេលយើងធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធយ៉ាងអង់អាចដើម្បីធ្វើនូវការកែតំរូវដ៏ត្រឹមត្រូវ នោះនឹងនាំយើងត្រឡប់មកលើផ្លូវវិញ។

សន្និសីទនេះ ត្រូវបានបកប្រែជា 92 ភាសា ហើយចាក់ផ្សាយនៅ 96 ប្រទេស តាមរយៈអព្ភូតហេតុនៃបច្ចេកវិជ្ជាទំនើប។ បងប្អូនជាច្រើនចូលរួមក្នុងសន្និសីទទូទៅតាមរយៈអ៊ិនធើរណែត។ បច្ចេកវិជ្ជាថ្មីបែបនេះ បានធ្វើឱ្យសារលិខិតនៃដំណឹងល្អអាចត្រូវបានផ្សព្វផ្សាយនៅជុំវិញពិភពលោក។ វិបសាយរបស់សាសនាចក្រ គឺគំរូដ៏ល្អនៃរបៀបដែលអ្នកអាចប្រើប្រាស់បច្ចេកវិជ្ជានេះ ជាធនធានដ៏អស្ចារ្យនៃការបំផុសគំនិត ជំនួយ និងការរៀនសូត្រ។ បច្ចេកវិជ្ជាទាំងនេះអាចជាពរជ័យសំរាប់អ្នកកាន់បព្វជិតភាពទាំងឡាយ សំរាប់ក្រុមគ្រួសាររបស់អ្នក និងសាសនាចក្រ។

ប៉ុន្តែសូមប្រយ័ត្ន។ បច្ចេកវិជ្ជាដូចគ្នានេះអាចអនុញ្ញាតឱ្យឥទ្ធិពលអាក្រក់ចូលមកក្នុងគេហដ្ឋានរបស់អ្នករាល់គ្នា។ អន្ទាក់ដ៏គ្រោះថ្នាក់ទាំងនេះ អាចកើតមានដោយគ្រាន់តែចុចលើកូនកណ្តុរនៃកុំព្យូទ័រតែម្តងប៉ុណ្ណោះ។ រូបភាពអាសគ្រាម អំពើហឹង្សា ការមិនចេះអត់ឱន និងអំពើមិនបរិសុទ្ធ បំផ្លាញក្រុមគ្រួសារ អាពាហ៍ពិពាហ៍ និងឆាកជីវិតរបស់បុគ្គលម្នាក់ៗ។ គ្រោះថ្នាក់ទាំងនេះ ត្រូវបានគេចែកចាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាច្រើន រួមមាន ទស្សនាវដ្តី សៀវភៅ ទូរទស្សន៍ ខ្សែភាពយន្ត និងតន្ត្រី ក៏ដូចជាអ៊ិនធើរណែតផងដែរ។ ព្រះអម្ចាស់នឹងជួយអ្នកឱ្យដឹង ហើយជៀសវាងពីអំពើអាក្រក់ទាំងនោះ។ វាគឺជាការស្គាល់គ្រោះថ្នាក់ជាមុន និងការកែតំរូវទៅផ្លូវដ៏ច្បាស់មួយ ដែលនឹងរក្សាអ្នកនៅក្នុងពន្លឺនៃដំណឹងល្អ។ ការសំរេចចិត្តតូចៗអាចនាំឱ្យមាននូវផលវិបាកធំៗ។

ការចូលទៅក្នុងការនិយាយលេងនៅតាមអ៊ិនធើរណែតដ៏ចម្លែក និងដ៏គ្រោះថ្នាក់ អាចនាំអ្នករាល់គ្នាទៅក្នុងបញ្ហាដែលនឹងរំខានដល់ជីវិតរបស់អ្នក។ ការដាក់កុំព្យូទ័រនៅក្នុងបន្ទប់ផ្ទាល់ខ្លួន ដែលសមាជិកគ្រួសារផ្សេងទៀតមិនអាចប្រើបាន អាចជាចំណុចចាប់ផ្តើមសំរាប់ដំណើរដែលបោកបញ្ឆោត និងគ្រោះថ្នាក់មួយ។

ប៉ុន្តែព្រះអម្ចាស់មិនតំរូវឱ្យមានតែទង្វើរខាងក្រៅនោះទេ ប៉ុន្តែជាការគិត និងអារម្មណ៍នៅក្នុងរបស់យើង ដើម្បីខិតជិតវិញ្ញាណនៃក្រិត្យវិន័យ។[16] ព្រះ "តម្រូវចិត្ត និងគំនិតដែលស្ម័គ្រតាម"។[17]

បព្វជិតភាពនៃព្រះ យើងមាននូវការទទួលខុសត្រូវ និងអំណាចនៃការដឹកនាំខ្លួនឯង : "ត្បិតមើលចុះ មិនសមឱ្យយើងត្រូវបញ្ជានូវគ្រប់អ្វី១ទាំងអស់ទេ" ព្រះអម្ចាស់បានបន្ទូលយ៉ាងដូច្នេះ ។ "មនុស្សលោកត្រូវខុសខ្វាហ៏ចូលរួមក្នុងប្រយោជន៍ល្អ ហើយប្រព្រឹត្តអ្វី១ជាច្រើនតាមបំណងចិត្តរបស់ខ្លួន ហើយនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន ត្បិតអំណាចគឺមាននៅក្នុងខ្លួនគេ" ។[18]

ព្រះវរបិតាសួគ៌របស់យើង បានជ្រាបពីមុនយើងបានមកកាន់ជីវិតរមែងស្លាប់នេះថា កម្លាំងអរិជ្ជមាននឹងទាញយើងឱ្យរសាត់ចេញពីផ្លូវរបស់យើង "ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" ។[19] នោះគឺជាហេតុផលដែលទ្រង់បានរៀបចំផ្លូវមួយសំរាប់យើងធ្វើការកែតំរូវ ។ តាមរយៈដំណើរការដ៏មានសេចក្ដីមេត្តាករុណានៃការកែប្រែចិត្តពិត និងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះអំពើបាបរបស់យើងអាចត្រូវបានអភ័យទោសឱ្យ ហើយយើងនឹង "មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ" ។[20]

ឆន្ទៈរបស់យើងដើម្បីប្រែចិត្ត បង្ហាញនូវការដឹងគុណរបស់យើងចំពោះអំណោយទានរបស់ព្រះនិងចំពោះសេចក្ដីស្រឡាញ់ និងការពលិកម្មរបស់ព្រះអង្គសង្គ្រោះ ដើម្បីជាប្រយោជន៍ដល់យើង ។ ព្រះបញ្ញត្តិ និងសេចក្ដីសញ្ញាបព្វជិតភាពផ្ដល់នូវការសាកល្បងនៃសេចក្ដីជំនឿ ការគោរពប្រតិបត្តិ និងសេចក្ដីស្រឡាញ់ *ចំពោះ* ព្រះ និងព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែសំខាន់ជាងនេះទៅទៀត បទបញ្ញត្តិទាំងនោះផ្ដល់នូវឱកាសដើម្បីពិសោធន៍នូវសេចក្ដីស្រឡាញ់ *ពី* ព្រះ និងដើម្បីទទួលសេចក្ដីរីករាយពេញលេញ ទាំងនៅក្នុងជីវិតនេះ និងនៅជីវិតខាងមុខ ។

ព្រះបញ្ញត្តិ និងសេចក្ដីសញ្ញាទាំងនេះរបស់ព្រះ គឺប្រៀបដូចជាការណែនាំខាងអាកាសចរណ៍មកពីស្ថានសួគ៌ ហើយនឹងដឹកនាំយើងដោយសុវត្ថិភាព ទៅកាន់គោលដៅដ៏នៅអស់កល្បជានិច្ចរបស់យើង ។ វាគឺជាគោលដៅមួយនៃភាពស្រស់ស្អាត និងភាពរុងរឿងហួសពីការយល់ ។ វាសក្តិសមទៅនឹងកិច្ចខិតខំនេះ ។ វាសក្តិសម ដោយធ្វើនូវការកែតំរូវដ៏សំខាន់នៅពេលនេះ ហើយបន្ទាប់មកដើរនៅតាមផ្លូវត្រូវនោះ ។

ចូរចងចាំ : ស្ថានសួគ៌នឹងមិនបានបំពេញដោយជនទាំងឡាយណាដែលមិនធ្លាប់ធ្វើខុសឡើយ ប៉ុន្តែពោរពេញទៅដោយជនទាំងឡាយណាដែលបានដឹងថា ពួកគេបានរសាត់ចេញពីផ្លូវ ហើយដែលបានតំរង់ផ្លូវរបស់ខ្លួន ដើម្បីត្រឡប់មកក្នុងពន្លឺនៃដំណឹងល្អវិញ ។

កាលណាយើងសន្សំទុកនូវពាក្យពេចន៍របស់ព្យាការី ហើយធ្វើតាមពាក្យទាំងនោះកាន់តែច្រើន នោះយើងនឹងយល់កាន់តែប្រសើរឡើង ពេលដែលយើងរសាត់ចេញពីផ្លូវ--- សូម្បីតែតាមរយៈបញ្ហោបន្តិចបន្តួចក៏ដោយ ។

## ចុះប្រសិនបើយើងបានរសាត់ចេញពីផ្លូវវិញ?

បងប្អូនប្រុសទាំងឡាយ មានជនទាំងឡាយដែលរឹងទទឹងដើម្បីធ្វើការកែប្រែផ្លូវឱ្យត្រឹមត្រូវ ហើយឥឡូវជឿថាពួកគេនៅពេលនេះឆ្ងាយពីផ្លូវរបស់ព្រះអម្ចាស់ដែលមិនអាចត្រឡប់មកវិញ មាននូវដំណឹងល្អទេ ។ ចំពោះពួកគេយើងសូមប្រកាសដំណឹងល្អ ដែលជាដំណឹងល្អនៃការប្រោសលោះ និងសេចក្ដីសង្គ្រោះ ។ មិនថាឡើយអ្នកដើរផ្លូវខុសប៉ុណ្ណាមិនថាឡើយអ្នកវង្វេងផ្លូវប៉ុណ្ណា ផ្លូវត្រឡប់មកវិញ គឺជាក់លាក់ ហើយច្បាស់លាស់ ។ សូមមករៀនពីព្រះវរបិតាថ្វាយនូវចិត្តសង្រេង និងវិញ្ញាណទន់ទាប ។ សូមមានជំនឿ ហើយជឿនៅលើអំណាច ដ៏ស្អាតស្អំនៃដង្វាយធួនជានិរន្តរ៍នៃព្រះយេស៊ូវគ្រីស្ទ ។ បើយើងសារភាព ហើយប្រែចិត្តពីអំពើបាបរបស់យើង ព្រះគឺស្មោះត្រង់ ហើយយុត្តិធម៌ក្នុង

ការអភ័យទោស និងលាងសំអាតយើងពីគ្រប់សេចក្តីមិនសុចរិតទាំងអស់ ។[21] "ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹង [ត្រូវធ្វើឱ្យ] បានសដូចហិមៈ" ។[22]

វាអាចជាផ្លូវដែលមិនងាយស្រួល ហើយវាតំរូវឱ្យមានការអប់រំខាងរូបកាយ និងការប្តេជ្ញាក្នុងចិត្ត ប៉ុន្តែទីបញ្ចប់របស់វា រុងរឿងហួសពីអាចពិពណ៌នាបាន ។ អ្នកមិនមែនវិនាសដោយទីបញ្ចប់ដែលគួរឱ្យភ័យខ្លាចនោះទេ ។ មនុស្សជាច្រើនចង់ជួយដល់អ្នក--- ក្រុមគ្រួសាររបស់អ្នក ប៊ីស្សព និងប្រធានស្តេក អ្នកដឹកនាំក្រុមរបស់អ្នក ហើយគ្រូបង្រៀនតាមផ្ទះរបស់អ្នក ។ ពិតប្រាកដណាស់ មិត្តភក្តិដ៏ល្អរបស់អ្នក គឺព្រះអង្គបង្កបង្កើតដ៏មានព្រះចេស្តា នៃសាកលលោក ។ បព្វជិតភាពដែលអ្នកកាន់ គឺជាបព្វជិតភាពរបស់ទ្រង់ ។ ទ្រង់យល់ពីទុក្ខព្រួយរបស់អ្នក ។ ទ្រង់ដឹងពីទុក្ខលំបាករបស់អ្នក ។ ទ្រង់ និងព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើងនឹងប្រទានពរ លួងលោម និងពង្រឹងអ្នក ទ្រង់នឹងដើរក្បែរអ្នក ហើយលើកអ្នកឡើងនៅពេលដែលអ្នកព្យាយាមធ្វើរឿងត្រឹមត្រូវ ។

បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំ អ្នករាល់គ្នាគឺពិតជាបុត្រាដ៏ជំរើស និងដ៏មានតម្លៃនៃព្រះវរបិតាសួគ៌ ។ ទ្រង់បានទុកព្រះទ័យលើអ្នករាល់គ្នាជាមួយនឹងអំណាចពិសិដ្ឋនៃបព្វជិតភាព ។ សូមកុំរសាត់ចេញពីផ្លូវ កុំរសាត់ចេញសូម្បីបន្តិចបន្តួចក៏ដោយ ។ ចូរស្តាប់ព្រះអម្ចាស់ជាព្រះរបស់អ្នក ហើយទ្រង់នឹងធ្វើចំពោះអ្នកនូវអ្វីដែលទ្រង់បានសន្យាថាធ្វើចំពោះសូល : ទ្រង់នឹងប្រទានឱ្យអ្នករាល់គ្នានូវដួងចិត្តថ្មីមួយ ធ្វើឱ្យអ្នកក្លាយជាមនុស្សថ្មី និងនៅជាប់ជាមួយនឹងអ្នករាល់គ្នាជានិច្ច ។

ខ្ញុំធ្វើទីបន្ទាល់ពីព្រះវរបិតាសួគ៌របស់យើង ដែលទ្រង់ស្គាល់ ហើយស្រឡាញ់អ្នក ។ ខ្ញុំសូមធ្វើទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ព្រះអង្គសង្គ្រោះរបស់យើង ដែលទ្រង់ជាអ្នកដឹកនាំនៃសាសនាចក្រនេះ ។ ប្រធាន ថូម៉ាស អេស ម៉នសុន គឺជាព្យាការីនៃព្រះសព្វថ្ងៃនេះ ។ ខ្ញុំសូមសម្តែងនូវសេចក្តីស្រឡាញ់ និងអំណរគុណចំពោះអ្នករាល់គ្នា ដែលជាមិត្ត និងបងប្អូនប្រុសនៃបព្វជិតភាពជាទីស្រឡាញ់របស់ខ្ញុំ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល Arthur Marcel, "Mount Erebus Plane Crash" www.abc.net.au/rn/ockhamsrazor/stories/2007/1814952.htm ។
2. សាំយូអែលទី1 9:2 ។
3. សូមមើល សាំយូអែលទី1 9:17 ។
4. សូមមើល សាំយូអែលទី1 10:23 ។
5. សូមមើល សាំយូអែលទី1 9:1 ។
6. សូមមើល សាំយូអែលទី1 10:7 ។
7. សូមមើល សាំយូអែលទី1 10:9 ។
8. សូមមើល សាំយូអែលទី1 10:6 ។
9. សូមមើល សាំយូអែលទី1 11:11 ។
10. សាំយូអែលទី1 13:5 ។

11. សាំយូអែលទី1 13:6 ។
12. សាំយូអែលទី1 13:13--14 ។
13. គ. និង ស. 84:26 ។
14. សូមមើល គ. និង ស. 84:38--39 ។
15. គ. និង ស. 82:3 ។
16. សូមមើល អាលម៉ា 12:12--14 គ. និង ស. 88:109 ។
17. គ. និង ស. 64:34 ។
18. គ. និង ស. 58:26--28 ។
19. រ៉ូម 3:23 ។
20. យ៉ូហាន 3:16 ។
21. សូមមើល យ៉ូហានទី 1 1:9 ។
22. អេសាយ 1:18 ។